ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក.

# ២០២៣

# របាយការណ៍

# ប្រចាំឆ្នាំ

គ្រឹះស្ថានឯកជន

# មាតិកា


| | |
|---|---|
| ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល | ០៣ |
| សារពីនាយកប្រតិបត្តិ | ០៤ |
| ប្រវត្តិក្រុមហ៊ុន | ០៥ |
| រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន | ០៦ |
| ផលិតផល និងសេវាកម្ម | ០៧ |
| របាយការណ៍សវនកម្មឯករាជ្យ | ០៩ |

# ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រុមហ៊ុនយើងខ្ញុំ គឺប្តេជ្ញាចិត្តក្លាយជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុដ៏ល្អឥតខ្ចោះនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលបាននូវទំនុកចិត្តពីនិយោជិត អតិថិជន និងសហគមន៍ តាមរយៈប្រតិបត្តិការដោយសុច្ចរិត និងតម្លាភាពគ្រប់ពេលវេលា។

## បេសកកម្ម

ដើម្បីបង្កើតភាពល្អឥតខ្ចោះនៃតម្លៃរបស់ភាគីពាក់ព័ន្ធ តាមរយៈការផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុដ៏ល្អបំផុត ដល់បុគ្គល និងសហគ្រាស ដើម្បីជម្រុញដល់សេដ្ឋកិច្ចប្រទេសកម្ពុជា។ តាមរយៈផលិតផលប្រកបដោយភាពច្នៃប្រឌិត សេវាកម្មបម្រើអតិថិជនដ៏ល្អឥតខ្ចោះ ការអភិវឌ្ឍបុគ្គលិក និងការប្តេជ្ញាចិត្តដើម្បីរក្សានិរន្តភាព យើងខ្ញុំនឹងសម្រេចឲ្យបាននូវមហិច្ឆតា និងព្យាយាមត្រួសត្រាយផ្លូវសម្រាប់ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាឲ្យកាន់តែល្អប្រសើរឡើងសម្រាប់ឆ្នាំខាងមុខ។

## តម្លៃស្នូល

ឆាយលីស ធ្វើតាមមតម្លៃស្នូល ៤ ដើម្បីសម្រេចឲ្យបាន
នូវបេសកកម្មរបស់យើងខ្ញុំ៖
ក្រុមហ៊ុនហិរញ្ញវត្ថុដ៏ឆ្នើមនៅតំបន់អាស៊ី ប៉ាស៊ីហ្វិក

| | |
|---|---|
| គុណតម្លៃ៖ | ភាពច្នៃប្រឌិត ដើម្បីសម្រេចបាននូវលទ្ធផលឈ្នះ ឈ្នះ |
| ការរីកលូតលាស់៖ | ត្រៀមរួចជាស្រេច ដើម្បីបន្តការសិក្សា និងការអភិវឌ្ឍជានិរន្តរភាព។ |
| ទំនុកចិត្ត៖ | ភាពស្មោះត្រង់ ការគោរព និងការបម្រើអតិថិជនឲ្យបានល្អ។ |
| វិន័យ៖ | ភាពក្លាហានក្នុងការទទួលខុសត្រូវ និងប្រតិបត្តិតាមផែនការអាជីវកម្ម។ |



# សាររបស់នាយកប្រតិបត្តិ



នៅក្នុងឆ្នាំ ២០២៣ សេដ្ឋកិច្ចកម្ពុជាបន្តងើបឡើងវិញក្នុងល្បឿនមួយគួរអោយគត់សំគាល់ បើទោះបីជាស្ថានភាពពិភពលោកមានការប្រកួតប្រជែងគ្នាក៏ដោយ អតិផរណានៅក្នុងប្រទេសក៏កំពុងស្ថិតក្រោមការគ្រប់គ្រងបន្តិចម្តងៗផងដែរ។ តែទោះជាយ៉ាងណាក៏ដោយ ហានិភ័យក៏នៅតែមាន ចាប់តាំងពីការកើនឡើងអត្រាការប្រាក់សកល។ គួរបញ្ជាក់ផងដែរថានៅក្នុងឆ្នាំ ២០២៣ យោងតាមការបង្ហាញរបស់ធនាគារជាតិនៃកម្ពុជា ទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានកើនឡើងរហូត ១.១% ស្មើនឹង ២.០ ពាន់ពាន់លានរៀល (៤៩៨.២ លានដុល្លារ) ខណៈដែលភតិសន្យាហិរញ្ញវត្ថុសរុបបានថយចុះមក -២.៣% ស្មើនឹង ១.៧ ពាន់ពាន់លានរៀល (៤២៦.៤ លានដុល្លារ) ដែលត្រូវបានបែងចែកទៅកាន់វិស័យផ្សេងៗដូចជាកសិកម្ម ២៥.៦%, គ្រួសារ ២៣.០%, សេវាកម្ម ១៩.៤%, ការដឹកជញ្ជូន ៤.៤%, សំណង់ ៣.៩%, ពាណិជ្ជកម្ម ៣.៥%, និងផ្សេងទៀត ២០.២% ។ វិស័យភតិសន្យាហិរញ្ញវត្ថុ បានចូលរួមចំណែកក្នុងការលើកកម្ពស់ ការដាក់បញ្ចូលហិរញ្ញវត្ថុដោយការផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ដល់អតិថិជនចំនួន ៩០,៣៨២ តាមរយៈការិយាល័យកណ្តាល និងសាខាសរុបចំនួន ៦៤ ទីតាំងទូទាំងប្រទេស។ សេវាភតិសន្យាហិរញ្ញវត្ថុមានលើចលនវត្ថុដូចជា ម៉ូតូ រថយន្ត គ្រឿងចក្រកសិកម្ម និងសំណង់ គ្រឿងសង្ហារិមគ្រឿងអេឡិចត្រូនិក នៅកម្ពុជាកំពុងកើនឡើងយ៉ាងខ្លាំងពីមួយត្រីមាសទៅមួយត្រីមាស។ វិស័យភតិសន្យាហិរញ្ញវត្ថុភាគច្រើនមានភាពតឹងរឹងក្នុងការចេញភតិសន្យាទៅកាន់ប្រជាជន។ ផលិតផលភតិសន្យាជារួមនៅក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ សម្រាប់ប្រាក់ចំណេញ ROA និង ROE ស្ថិតនៅកម្រិត ០.៨% និង ២.៤% ខណៈពេលដែលសមាមាត្រ NPL គឺនៅ ៥.១%។ ចំណែកផលិតផលភតិសន្យា ឆាយលីស រ៉ូយ៉ាល់ នៅតែប្រុងប្រយ័ត្នខ្ពស់ដើម្បីធានាថាយុទ្ធសាស្ត្រទីផ្សាររបស់យើងអោយមានភាពធន់ ហើយកំណើននោះកាន់តែមាននិរន្តរភាព។

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ឆាយលីស រ៉ូយ៉ាល់ បានកែប្រែផលប័ត្ររបស់ខ្លួនឡើងវិញតាមរយៈការកែតម្រូវឥណទាន និងផលិតផល ដើម្បីធានាបាននូវកំណើនរបស់យើងប្រកបដោយគុណភាព។ យើងរីករាយ ដែលអត្រាសេវាភតិសន្យាហិរញ្ញវត្ថុរបស់យើងត្រូវបានគ្រប់គ្រងក្នុងកម្រិតដ៏ត្រឹមត្រូវមួយ បើទោះបីជាកំណើននៃផលប័ត្ររបស់យើងមិនដំណើរការល្អដូចដែលយើងបានគ្រោងទុកក៏ដោយ។

ប្រាក់ចំណេញរបស់ក្រុមហ៊ុននៅតែរងផលប៉ះពាល់ ដោយការបង្កើនការចំណាយមូលនិធិ។ ការស្វែងរកប្រភពមូលនិធិប្រសើរជាងមុននៅតែជាកិច្ចការអាទិភាពខ្ពស់សម្រាប់ប្រតិបត្តិការក្រុមហ៊ុន។

# ប្រវត្តក្រុមហ៊ុន

ឆាយលីស គ្រុប គឺជាកន្លែងដែលល្អបំផុតសម្រាប់សមត្ថភាពផ្នែកហរិញ្ញវត្ថុ

ក្រុមហ៊ុនឆាយលីស ហូឌីង លីមីធីត គឺជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុអន្តរជាតិមួយ ដែលបានបង្កើត ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក ជាក្រុមហ៊ុនក្រោមចំណុះថ្មីមួយ នៅរាជធានីភ្នំពេញ ក្នុងខែមករា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុនឆាយលីស រ៉ូយ៉ាល់ លីសស៊ីង ម.ក គឺជាក្រុមហ៊ុនដែលវិនិយោគរួមគ្នាមួយ ដែលបង្កើតឡើងដោយក្រុមហ៊ុនឆាយលីស គ្រុប និងក្រុមហ៊ុនរ៉ូយ៉ាល់ គ្រុប។ អាជីវកម្មស្នូលរបស់ក្រុមហ៊ុនគឺភតិសន្យាហិរញ្ញវត្ថុចំពោះរថយន្ត និងគ្រឿងម៉ាស៊ីន។ យើងខ្ញុំផ្តល់ជូននូវឱកាសសម្រាប់បេក្ខជនទាំងអស់ដែលមានស្មារតីក្រុម ទឹកចិត្តបម្រើសេវាកម្ម គំនិតច្នៃប្រឌិតចូលរួមជាមួយពួកយើងខ្ញុំ។





ក្រុមហ៊ុនឆាយលីស ហូឌីង លីមីធីត គឺជាក្រុមហ៊ុនភតិសន្យាដែលបានចុះបញ្ជីនៅលើទីផ្សារភាគហ៊ុនតៃវ៉ាន់ ជាមួយនឹងបទពិសោធន៍អាជីវកម្មហិរញ្ញវត្ថុជាង៣៥ឆ្នាំ និងមានប្រតិបត្តិការនៅ តៃវ៉ាន់ ចិន ថៃ វៀតណាម ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។ អាជីវកម្មស្នូលគឺ ផ្តល់សេវាហិរញ្ញវត្ថុចម្រុះដល់សហគ្រាសធុនតូច និង មធ្យម (SMEs) រួមបញ្ចូលទាំង ភតិសន្យា ការលក់ដោយបង់រំលស់ ការផ្តល់ហិរញ្ញវត្ថុ និងការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ ។

ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ត្រូវបានគេទទួលស្គាល់ ថាជាក្រុមហ៊ុនដែលរឹងមាំ និងមានអាជីវកម្មចម្រុះ។ បង្កើតឡើងជាក្រុមហ៊ុនវិនិយោគទុនមួយ ដែលវិនិយោគក្នុងវិស័យជាច្រើន ដែលរួមមាន វិស័យទូគមនាគមន៍ ប្រព័ន្ធផ្សព្វផ្សាយ ធនាគារ ធានារ៉ាប់រង រមណីយដ្ឋាន ការអប់រំ អចលនទ្រព្យ ពាណិជ្ជកម្ម និងវិស័យកសិកម្ម ។

# រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន

- ការិយាល័យប្រធានក្រុមប្រឹក្សាភិបាល
  - ប្រធានក្រុមប្រឹក្សាភិបាល
- ការិយាល័យនាយកប្រតិបត្តិ
  - នាយកគ្រប់គ្រង
    - នាយកដ្ឋានផ្នែកលក់
    - នាយកដ្ឋានផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ
    - នាយកដ្ឋានផ្នែកវាយតម្លៃឥណទាន
    - នាយកដ្ឋានផ្នែកផែនការ
    - នាយកដ្ឋានផ្នែកបម្រើសេវាកម្មអតិថិជន
    - នាយកដ្ឋានផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា
    - នាយកដ្ឋានផ្នែកច្បាប់ និងប្រមូលទុន
    - នាយកដ្ឋានផ្នែកធនធានមនុស្ស និងរដ្ឋបាល

# ផលិតផល និងសេវាកម្ម

## សេវាកម្ម

ភតិសន្យាហិរញ្ញវត្ថុ គឺជាប្រភពមូលធនបត់បែនសម្រាប់សហគ្រាស និងបុគ្គល។ សម្រាប់សហគ្រាស វាផ្តល់ដើមទុនហិរញ្ញវត្ថុសម្រាប់វិនិយោគ ដែលរួមមានគ្រឿងម៉ាស៊ីន រថយន្ត (រថយន្តដឹកអ្នកដំណើរ រថយន្តក្រុង រថយន្តដឹកទំនិញ) និងសម្ភារៈបរិក្ខារការិយាល័យ។ សម្រាប់បុគ្គល វាផ្តល់ហិរញ្ញប្បទានសម្រាប់អតិថិជន ទៅលើរថយន្ត និងទំនិញប្រើប្រាស់បានយូរ។

## គុណសម្បត្តិនៃហិរញ្ញប្បទាន

- នីតិវិធីនៃពាក្យសុំមានភាពឆាប់រហ័ស និងសាមញ្ញដើម្បីបំពេញតាមតម្រូវពេលវេលារបស់អតិថិជន
- ការផ្តល់ហិរញ្ញប្បទានរយៈពេលវែង និងការទូទាត់ថេរ ធ្វើឲ្យការគ្រប់គ្រងចំណាយកាន់តែមានភាពងាយស្រួល
- បញ្ញត្តិ និងលក្ខខណ្ឌបត់បែន ដោយគ្មានទ្រព្យបញ្ចាំ
- ប្រភពមូលនិធិជំនួស ដើម្បីការពារដើមទុនដែលមានស្រាប់សម្រាប់ការប្រើប្រាស់ផ្សេងទៀត



# ផលិតផល និងសេវាកម្ម

## ភតិសន្យាហិរញ្ញវត្ថុក្នុងស្រុក

ភតិសន្យាហិរញ្ញវត្ថុក្នុងស្រុក ពាក់ព័ន្ធជាមួយក្រុមហ៊ុនភតិសន្យា ដែលតាងនាមឲ្យភតិកៈដើម្បីទិញទ្រព្យពីអ្នកផ្គត់ផ្គង់ក្នុងស្រុក និងជួលត្រឡប់ទៅឲ្យភតិកៈវិញ តាមកាលវិភាគទូទាត់ប្រាក់ជួលក្នុងកិច្ចព្រមព្រៀងភតិសន្យា។




## ការលក់ និង ការជួលវិញ

ការលក់ និងជួលវិញ ពាក់ព័ន្ធជាមួយក្រុមហ៊ុនភតិសន្យា ដែលបានទិញទ្រព្យដែលកាន់កាប់ដោយភតិកៈម្នាក់ ហើយជួលទ្រព្យដែលបានទិញនេះវិញ ទៅឲ្យភតិកៈម្នាក់នោះ ក្រោមភតិសន្យាហិរញ្ញវត្ថុ។ នៅក្នុងប្រតិបត្តិការលក់ និងជួលវិញ ភតិបតីក៏ជាអ្នកផ្គត់ផ្គង់ផងដែរ ។



# របាយការណ៍ហិរញ្ញវត្ថុ

## ទ្រព្យសកម្មសរុប




## ចំណូលសរុប




## មូលធនសរុប




## ចំណាយសរុប




## ធនធានមនុស្សសរុប



អាគារ ឃីស្តូន លេខ ១៤៦ (ជាន់ទី១១), មហាវិថី ព្រះនរោត្តម(41), សង្កាត់ ទន្លេបាសាក់,
ខណ្ឌ ចំការមន, រាជធានី ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ: (៨៥៥) ២៣ ៩០១ ៧២៨,
ទូរសារ: (៨៥៥) ២៣ ៩០១ ៧៦៨,
គេហទំព័រ: www.chailease.com.kh/Leasing